00989632

E310

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 29 / 05 / 2014
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

# ដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រមនៅក្នុងសំណុំរឿង ០០២/០១

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

E310

## អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ អនុលោមតាម សាលដីកាលើបណ្តឹងឧទ្ធរណ៍ របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ (អបជ) ឯកសារ D427/4/15 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១១ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ (អបជ) ឯកសារ D427/2/15 និង ឯកសារ D427/3/15 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ និង សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ (អបជ) ឯកសារ D427/1/30 ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១។

**រំលឹកឡើងវិញ** នូវការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេលបិទបញ្ចប់សវនាការកាលពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៣ ថា អង្គជំនុំជម្រះនឹងជូនដំណឹងទៅដល់ភាគីនានា និងសាធារណជន អំពីកាលបរិច្ឆេទនៃការប្រកាសសាលក្រម នៅក្នុងពេលវេលាមួយសមស្រប។

**អនុលោមតាម** វិធាន ៩៨ នៃវិធានផ្ទៃក្នុង។

### ហេតុដូច្នេះ

**ជូនដំណឹង** ដល់ភាគីនានាថា សាលក្រមនៃសំណុំរឿង ០០២/០១ ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន នឹងត្រូវប្រកាសនៅថ្ងៃ ព្រហស្បតិ៍ ទី ០៧ ខែ សីហា ឆ្នាំ ២០១៤ នៅក្នុងសាលសវនាការធំនៃ អ.វ.ត.ក វេលាម៉ោង ៩:០០ ព្រឹក។

**បង្គាប់ថា** ដីកានេះនឹងត្រូវជូនដំណឹងដល់ភាគីនានា និងការិយាល័យរដ្ឋបាល ព្រមទាំងត្រូវផ្សព្វផ្សាយលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក។

ភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៤

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE DE PREMIÈRE INSTANCE